ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៤០៤ ព.ណ.ករ.ពា...

ថ្ងៃព្រហស្បតិ៍ ១០កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០២៦

# សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូន លោក-លោកស្រី ជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជនទាំងអស់គ្នាឱ្យបានជ្រាបថា ក្រសួងពាណិជ្ជកម្មនឹងចូលរួម **ពិព័រណ៍ពាណិជ្ជកម្មម្ហូបអាហារអន្តរជាតិ «SIAL PARIS 2026»** ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៧-២១ ខែតុលា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌលពិព័រណ៍ Paris Nord Villepinte ទីក្រុងប៉ារីស សាធារណរដ្ឋបារាំង។ ព្រឹត្តិការណ៍ពិព័រណ៍នេះ គឺជាពិព័រណ៍អាហារ និងភេសជ្ជៈធំបំផុតលំដាប់ពិភពលោក ដែលដើរតួនាទីដ៏សំខាន់ក្នុងការតាំងបង្ហាញពីគំនិតច្នៃប្រឌិតថ្មីៗ ការផ្ដល់ឱកាសដល់ការបង្កើនបណ្ដាញទំនាក់ទំនង និងការស្វែងយល់ពីនិន្នាការថ្មីៗក្នុងឧស្សាហកម្មម្ហូបអាហារ និងភេសជ្ជៈ។ ព្រឹត្តិការណ៍នេះ ត្រូវបានបែងចែកជា ៨ផ្នែក ដែលក្នុងផ្នែកនីមួយៗផ្ដោតសំខាន់លើវិស័យផ្សេងៗគ្នា ពាក់ព័ន្ធនឹងឧស្សាហកម្មម្ហូបអាហារ និងភេសជ្ជៈ ដោយក្នុងនោះរួមមាន៖ អាហារកែច្នៃ អាហារឆ្អិនស្រាប់(ready-to-eat food) គ្រឿងផ្សំ គ្រឿងទេស នំចំណី បង្អែម ភេសជ្ជៈ ផលិតផលទឹកដោះគោ ផលិតផលសរីរាង្គ និងកសិផល។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មសូមអញ្ជើញ លោក-លោកស្រី ជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជន ដែលមានបំណងចង់ចូលរួមតាំងបង្ហាញនូវផលិតផលទំនិញជាអាហារ និងភេសជ្ជៈនៅក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមធ្វើការទំនាក់ទំនងមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ដែលមានអាសយដ្ឋានដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឱ្យបានមុន **ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦**។

ក្រសួងពាណិជ្ជកម្មសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រី ជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជន នឹងចូលរួមក្នុងព្រឹត្តិការណ៍នេះ ព្រមទាំងចាប់យកឱកាសដើម្បីអភិវឌ្ឍន៍អាជីវកម្ម និងពង្រីកសកម្មភាពវិនិយោគ។ សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទាក់ទងមកមន្ត្រីសម្របសម្រួលតាមរយៈលេខទូរស័ព្ទ +៨៥៥ ៨៧ ៧៥៥ ៥៥១ / +៨៥៥ ៧៧ ៣៦១ ៨៣៦ ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម **១២៦៦** ឬតាមរយៈអ៊ីម៉ែល tong.rita@moc.gov.kh / oun.veasna@moc.gov.kh។៚

សូមអរគុណ!

សម្រាប់ចុះឈ្មោះ:

GO.gov.KH

**KINGDOM OF CAMBODIA**
**Nation - Religion - King**

**Ministry of Commerce**
N°0504 MOC.D/EA

Phnom Penh, 12 February 2026

# ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform traders, producers, investors, and the public that the Ministry of Commerce is going to participate in the international expo **"SIAL PARIS 2026"**, to be held from 17-21 October 2026 at Paris Nord Villepinte, Paris, French Republic. This expo is the world's largest food and beverage trade fair and serves as a major platform for showcasing innovations, fostering networking opportunities, and exploring emerging trends in the food and beverage industry. SIAL Paris features eight specialized trade shows, and each trade show is dedicated to key sectors of the industry including processed and ready-to-eat foods, condiments and seasonings, confectionery and bakery, beverages and dairy, as well as organic and agricultural products.

In this regard, the Ministry of Commerce would like to cordially invite Cambodian traders, producers, investors, and the public who are interested in showcasing their products and services at **SIAL PARIS 2026** to submit their Call for Interest applications to the Department of Exhibition Affairs, Directorate General of Trade Promotion, Ministry of Commerce at Lot No. 19-16, Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh by **21st February 2026 at the latest**.

The Ministry of Commerce encourages all stakeholders to seize this exceptional opportunity to expand their business networks, explore new markets, and enhance investment activities on a global scale. For further information, please contact the official in charge via tel +855 87 755 551 / +855 77 361 836 / MOC Call Center 1266 or email: tong.rita@moc.gov.kh / oun.veasna@moc.gov.kh.

**THANK YOU!**

SCAN FOR INTERESTS

GO.gov.kh

# SIAL PARIS 2026

World's Largest Food Innovation Exhibition

## 17-21 OCTOBER 2026

### PARIS NORD VILLEPINTE, PARIS, FRENCH REPUBLIC

Processed and Ready-to-Eat Foods, Condiments and Seasonings, Confectionery and Bakery, Baverages and Diary, As well as Organic and Agricultural Products

**CAMBODIA**
**BASKET OF WONDERS**

Join with the Ministry of Commerce to seize this exceptional opportunity on a global scale